សំណើរសុំ

ការអនុវត្តកញ្ចប់ការប្រជុំប្រចាំត្រីមាស

## ១. សេចក្តីផ្តើមៈ

ការប្រជុំត្រួតពិនិត្យការអនុវត្តប្រចាំត្រីមាស (QPRM) គឺវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រ និងបទអន្តរាគមន៍ប្រចាំត្រីមាស ស្របតាមយៈផែនការយុទ្ធសាស្ត្រជាតិ និងផែនការតាមដាន និងវាយតម្លៃ ដើម្បីបញ្ចប់របេងនៅកម្រិតស្រុកប្រតិបត្តិ។ ការប្រជុំត្រួតពិនិត្យការអនុវត្តប្រចាំត្រីមាស គឺជាការជំរុញឲ្យអ្នកអភិបាលរបេងស្រុកប្រតិបត្តិការប្រើប្រាស់ទិន្នន័យ ដោយធ្វើបច្ចុប្បន្នភាពតារាងសង្ខេបនៃសូចនាករជាក់លាក់ដែលបញ្ជូនមកពីមូលដ្ឋានសុខាភិបាល ដើម្បីធ្វើបទបង្ហាញក្នុងអង្គប្រជុំការប្រជុំត្រួតពិនិត្យការអនុវត្តប្រចាំត្រីមាស ដោយធៀបជាមួយគោលដៅជាតិ និងថ្នាក់ក្រោមជាតិ។ ការត្រួតពិនិត្យទិន្នន័យសមស្របមុនពេលពិភាក្សាក្នុងអង្គប្រជុំ និងផែនការសកម្មភាពក្រោយសម័យប្រជុំ គឺចាំបាច់ ដើម្បីវាស់វែងគុណភាពទិន្នន័យពីមូលដ្ឋានសុខាភិបាល ដើម្បីឱ្យទិន្នន័យដែលបានបង្កើតនៅមណ្ឌលសុខភាព និងថងក្រុងនៅកម្រិតស្រុកប្រតិបត្តិ មានគុណភាព និងអាចប្រើប្រាស់សម្រាប់ការតស៊ូមតិគោលនយោបាយទៅកាន់កម្រិតខ្ពស់។ ឧបករណ៍ត្រួតពិនិត្យគុណភាពទិន្នន័យ និងមគ្គុទេសណ៍ណែនាំការប្រើប្រាស់ឧបករណ៍ ត្រូវបានបង្ហាញ និងអ្នកអភិបាលស្រុកប្រតិបត្តិរបេងបានទទួលការបណ្តុះបណ្តាល និងប្រើប្រាស់ឧបករណ៍នោះ។ បន្ថែមលើឧបករណ៍ត្រួតពិនិត្យគុណភាពទិន្នន័យ នឹងមានការពិភាក្សាទៅលើការសូចនាការតាមដាន និងវាយតម្លៃរបេងដែលប្រមូលបានពីមូលដ្ឋានសុខាភិបាល និងរៀបចំផ្ទាំងទិន្នន័យមូលដ្ឋានសុខាភិបាលនៅកម្រិតស្រុកប្រតិបត្តិ។ ចុងក្រោយ ការប្រជុំត្រួតពិនិត្យការអនុវត្តប្រចាំត្រីមាស ជាផ្លូវមួយដើម្បីធ្វើអន្តរកម្មជាមួយបណ្តាមូលដ្ឋានសុខាភិបាល ធៀបការអនុវត្ត រៀនពីការអនុវត្តល្អ កំណត់បញ្ហាគុណភាពទិន្នន័យ និងគម្លាតនៃការអនុវត្តជាមួយនឹងផែនការសកម្មភាពកែតម្រូវ។

គោលដៅនៃប្រព័ន្ធតាមដាន និងវាយតម្លៃជំងឺរបេង (M&E) នៅកម្ពុជា គឺដើម្បីផលិតទិន្នន័យមានគុណភាពដែលប្រើសម្រាប់ការតាមដានជំងឺរបេងជាប្រចាំ។ ការតាមដានវឌ្ឍនភាពឆ្ពោះទៅរកគោលដៅរបស់កម្មវិធីរបេងជាតិ និងជូនដំណឹងដល់ការសម្រេចចិត្តលើការរៀបចំផែនការកម្មវិធី ការគ្រប់គ្រង ការបង្កើតគោលនយោបាយ និងការបែងចែកធនធាន។ ទិន្នន័យដែលបង្កើតដោយប្រព័ន្ធ TB M&E ត្រូវតែមានគុណភាពខ្ពស់ និងអាចជឿទុកចិត្តបាន ដូច្នេះអ្នកធ្វើការសម្រេចចិត្តនៅគ្រប់កម្រិតនៃកម្មវិធីអាចពឹងផ្អែកលើទិន្នន័យ និងប្រើប្រាស់ទិន្នន័យនោះបង្កើនប្រសិទ្ធភាពនៃការគ្របដណ្តប់ និងគុណភាពនៃសេវាថែទាំជំងឺរបេងឆ្ពោះទៅរកការបញ្ចប់ជំងឺរបេងនៅកម្ពុជា។

ការត្រួតពិនិត្យគុណភាពទិន្នន័យ (DQR) ត្រូវបានដកស្រង់ចេញពីម៉ូឌុល DQR របស់អង្គការសុខភាពពិភពលោក ហើយត្រូវបានរចនាឡើងដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យគុណភាពទិន្នន័យ ដែលធ្វើឡើងជាប្រចាំតាមរយៈការពិនិត្យឯកសារ និងការចុះអភិបាល។ បញ្ជីត្រួតពិនិត្យនេះនឹងជួយកំណត់ និងដោះស្រាយបញ្ហាគុណភាពទិន្នន័យជាប្រព័ន្ធនៅទូទាំងមូលដ្ឋានសុខាភិបាល (មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក) ឬស្រុកប្រតិបត្តិ (ODs)។ ការត្រួតពិនិត្យគុណភាពទិន្នន័យនឹងកំណត់តំបន់នៃការកែលម្អ និងជួយជូនដំណឹងអំពីសកម្មភាពកែតម្រូវ។

កញ្ចប់រួមជាមួយនឹងធាតុផ្សំសំខាន់ទាំងពីរនៃការវាស់វែងការអនុវត្ត ផ្ទាំងទិន្នន័យមណ្ឌលសុខភាព ត្រូវបានផ្តួចផ្តើមដើម្បីតាមដានសមិទ្ធផលកម្មវិធីនៅកម្រិតមណ្ឌលសុខភាព។

## ២. គោលបំណង៖

- ដើម្បីជួយ/គាំទ្រអ្នកអភិបាលរបេងស្រុកប្រតិបត្តិ ក្នុងការរៀបចំកញ្ចប់ QPRM ដែលរួមមាន ផ្ទាំងទិន្នន័យស្តីពីគុណភាពទិន្នន័យ ផ្ទាំងទិន្នន័យមណ្ឌលសុខភាព បញ្ជីត្រួតពិនិត្យM&E និងជំនួយការងារ
- ដើម្បីណែនាំអ្នកអភិបាលរបេងស្រុកប្រតិបត្តិ ក្នុងការដឹកនាំកិច្ចប្រជុំ QPRM តាមគោលការណ៍ណែនាំQPRM
- ដើម្បីពិគ្រោះយោបល់ជាមួយ CENAT និងថ្នាក់ក្រោមជាតិអំពីរបៀបអនុវត្តកញ្ចប់ QPRM ទូទាំងប្រទេស

## ៣. វិធីសាស្ត្រ៖

ជាការចុះពិនិត្យមូលដ្ឋានចំនួនពីរថ្ងៃទៅកាន់ស្រុកប្រតិបត្តិដែលបានកំណត់។ TBDIAH រួមជាមួយកម្មវិធីជាតិនឹងចុះទៅធ្វើការក្នុង ODs ចំនួនពីរ។ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនេះ TBDIAH នឹងផ្តួចផ្តើម និងបង្ហាញ/បណ្តុះបណ្តាលកញ្ចប់ QPRM និងគោលបំណងទៅកាន់អ្នកអភិបាលរបេងស្រុកប្រតិបត្តិ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះគឺដើម្បីបង្វឹកដល់អ្នកអភិបាលរបេងស្រុកប្រតិបត្តិ ក្នុងការដឹកនាំកិច្ចប្រជុំ ត្រួតពិនិត្យលទ្ធផលការងាររបស់ពួកគេ។ ការប្រជុំជាក់ស្តែងនឹងត្រូវបានរៀបចំនៅក្នុង OD ដែលបានជ្រើសរើសមួយ ហើយអ្នកអភិបាលរបេងស្រុកប្រតិបត្តិមកពីស្រុកប្រតិបត្តិផ្សេងៗទៀត នឹង សង្កេតមើល /ជួយក្នុងកិច្ចប្រជុំ។

**ថ្ងៃទី ០៖**

សារ៉ាឌី នឹងពិភាក្សាជាមួយអ្នកអភិបាលរបេងខេត្ត និងអ្នកអភិបាលរបេងស្រុកប្រតិបត្តិ ដើម្បីធានា ថាកាលវិភាគរៀបចំផែនការមានភាពងាយស្រួលសម្រាប់អ្នកអភិបាលរបេងស្រុកប្រតិបត្តិ ក្នុងការរៀបចំ QPRM និងសម្រាប់ ODs ផ្សេងទៀតនៅក្នុងខេត្ត ដើម្បីចូលរួម និងសង្កេតមើលពីរបៀបធ្វើ QPRM ។

**ថ្ងៃទី ១៖**

**ទីកន្លែង៖ ការិយាល័យសុខាភិបាលខេត្ត**

ក្រុមការងារ TBDIAH រួមទាំងមន្ត្រី CENAT មកពីថ្នាក់ជាតិ នឹងជួបប្រជុំជាមួយ អ្នកអភិបាលរបេងស្រុកប្រតិបត្តិ ដើម្បី៖

- ណែនាំអ្នកអភិបាលរបេងស្រុកប្រតិបត្តិពី QPRM៖ ដែលរួមមានទាំង៖ ជំនួយការងារ QPRM ឧបករណ៍ DQR និងផ្ទាំងទិន្នន័យស្តីពីគុណភាពទិន្នន័យ បញ្ជីត្រួតពិនិត្យM&E ផ្ទាំងទិន្នន័យមណ្ឌលសុខភាព
- តំរង់ទិសលើគោលការណ៍ណែនាំការអនុវត្ត QPRM
- អនុវត្តស្តីពីរបៀបបំពេញ និងប្រើប្រាស់ផ្ទាំងទិន្នន័យមណ្ឌលសុខភាព

**ថ្ងៃទី ២៖**

**ទីកន្លែង៖ ការិយាល័យស្រុកប្រតិបត្តិដែលបានជ្រើសរើស**

**ពេលព្រឹក៖** អ្នកអភិបាលរបេងស្រុកប្រតិបត្តិដែលបានកំណត់ នឹងដឹកនាំកិច្ចប្រជុំជាមួយបុគ្គលិកមណ្ឌលសុខភាពដែលធ្វើការជាមួយកម្មវិធីរបេង

**ពេលរសៀល៖** អ្នកអភិបាលរបេងស្រុកប្រតិបត្តិ និងមន្ត្រី CENAT ពិភាក្សាអំពីការអនុវត្ត QPRM ។ TB DIAH នឹងបញ្ជាក់បន្ថែម ប្រសិនបើមានការភ័ន្តច្រឡំណាមួយនៅក្នុង QPRM

**៤. លទ្ធផលរំពឹងទុក៖**

- អ្នកអភិបាលរបេងស្រុកប្រតិបត្តិ អាចអនុវត្តកិច្ចប្រជុំត្រួតពិនិត្យប្រចាំត្រីមាស ដោយប្រើប្រាស់ កញ្ចប់ QPRM
- កញ្ចប់ QPRM ដែលត្រូវបានអនុម័តដោយ CENAT ដើម្បីត្រូវបានអនុវត្តនៅក្នុង ODs ទាំងអស់។

**៥. អ្នកចូលរួម៖**

- អ្នកអភិបាលរបេងខេត្ត មកពីខេត្តចំនួនពីរ (ចំនួន ២នាក់/ខេត្ត)
- អ្នកអភិបាលរបេងស្រុកប្រតិបត្តិ៖ ១៣នាក់
- បុគ្គលិកមណ្ឌលសុខភាព (មន្ត្រីរបេង) ច្រើនបំផុត ២០នាក់x២ស្រុកប្រតិបត្តិ (១OD/ខេត្ត)
- TBDIAH៖ ៤នាក់
- សមាជិកថ្នាក់ជាតិ (ការិយាល័យបច្ចេកទេស MIS)៖ ៥នាក់

1. Dr.  Khun Kim Eam
2. Dr. Nou Chanly
3. Dr. Chhouv Krykolaprath
4. Dr. Long Ngeth
5. Mr. Mourn Phearom

**កាលវិភាគ៖**

**ខេត្តទី១៖ តាកែវ** **កាលបរិច្ឆេទ៖ តុលា ១៩-២០ ២០២៣**

| ពេលវេលា | សកម្មភាព | សម្របសម្រួលដោយ |
|---|---|---|
| **ថ្ងៃទី១** | | |
| 08:00 – 09:00 | ជួបប្រជុំជាមួយអ្នកអភិបាលរបេងខេត្ត/ស្រុកប្រតិបត្តិ និងបង្ហាញពីគោលបំណងនៃការទស្សនៈកិច្ច | CENAT/TB DIAH |
| 09:00 – 10:00 | បង្ហាញកញ្ចប់ QPRM (រួមមាន៖ ការត្រួតពិនិត្យគុណភាពទិន្នន័យ បញ្ជីត្រួតពិនិត្យ M&E ផ្ទាំងទិន្នន័យ និងជំនួយការងារ) | CENAT |
| 10:00 – 11:30 | បង្ហាញគោលការណ៍ QPRM | TB DIAH |
| 11:30 – 13:30 | សម្រាកអាហារថ្ងៃត្រង់ | |
| 13:30 – 14:00 | បង្ហាញបញ្ជីត្រួតពិនិត្យ M&E (M&E Checklist) | CENAT |
| 14:00 – 16:00 | បង្ហាញ និងបញ្ចូលទិន្នន័យនៅក្នុងទម្រង់ផ្ទាំងទិន្នន័យ (Excel នៃស្រុកប្រតិបត្តិនីមួយៗ) | CENAT |
| 16:00 – 17:00 | សង្ខេបពីឧបករណ៍ត្រួតពិនិត្យគុណភាពទិន្នន័យ និងបញ្ចូលទិន្នន័យនៅក្នុងទម្រង់ DQR (Excel) | TB DIAH |
| **ថ្ងៃទី២** | | |
| 08:00 – 11:30 | សង្កេតការអនុវត្តការប្រជុំ QPRM | TB OD supervisor |
| 11:30 – 13:30 | សម្រាកអាហារថ្ងៃត្រង់ | |
| 13:30 – 16:00 | ពិភាក្សាក្រោយកិច្ចប្រជុំ QPRM៖<br>• កំណត់ត្រាកិច្ចប្រជុំ QPRM និងចែករំលែកទៅកាន់ដៃគូពាក់ព័ន្ធ<br>• ចំណុចសកម្មភាពដែលត្រូវតាមដាន និងតាមដានវឌ្ឍនភាព | CENAT<br>TB OD supervisor<br>TB DIAH |

**ខេត្តទី១៖ ត្បូងឃ្មុំ** **កាលបរិច្ឆេទ៖ តុលា ២៤-២៥ ២០២៣**

| ពេលវេលា | សកម្មភាព | សម្របសម្រួលដោយ |
| --- | --- | --- |
| **ថ្ងៃទី១** | | |
| 08:00 – 09:00 | ជួបប្រជុំជាមួយអ្នកអភិបាលរបេងខេត្ត/ស្រុកប្រតិបត្តិ និងបង្ហាញពីគោលបំណងនៃការទស្សនៈកិច្ច | CENAT/TB DIAH |
| 09:00 – 10:00 | បង្ហាញកញ្ចប់ QPRM (រួមមាន៖ ការត្រួតពិនិត្យគុណភាពទិន្នន័យ បញ្ជីត្រួតពិនិត្យ M&E ផ្ទាំងទិន្នន័យ និងជំនួយការងារ) | CENAT |
| 10:00 – 11:30 | បង្ហាញគោលការណ៍ QPRM | TB DIAH |
| 11:30 – 13:30 | សម្រាកអាហារថ្ងៃត្រង់ | |
| 13:30 – 14:00 | បង្ហាញបញ្ជីត្រួតពិនិត្យ M&E (M&E Checklist) | CENAT |
| 14:00 – 16:00 | បង្ហាញ និងបញ្ចូលទិន្នន័យនៅក្នុងទម្រង់ផ្ទាំងទិន្នន័យ (Excel នៃស្រុកប្រតិបត្តិនីមួយៗ) | CENAT |
| 16:00 – 17:00 | សង្ខេបពីឧបករណ៍ត្រួតពិនិត្យគុណភាពទិន្នន័យ និងបញ្ចូលទិន្នន័យនៅក្នុងទម្រង់ DQR (Excel) | TB DIAH |
| **ថ្ងៃទី២** | | |
| 08:00 – 11:30 | សង្កេតការអនុវត្តការប្រជុំ QPRM | TB OD supervisor |
| 11:30 – 13:30 | សម្រាកអាហារថ្ងៃត្រង់ | |
| 13:30 – 16:00 | ពិភាក្សាក្រោយកិច្ចប្រជុំ QPRM៖<br>• កំណត់ត្រាកិច្ចប្រជុំ QPRM និងចែករំលែកទៅកាន់ដៃគូពាក់ព័ន្ធ<br>• ចំណុចសកម្មភាពដែលត្រូវតាមដាន និងតាមដានវឌ្ឍនភាព | CENAT<br>TB OD supervisor<br>TB DIAH |

This publication was produced with the support of the United States Agency for International Development (USAID) under the terms of the TB Data, Impact Assessment and Communications Hub (TB DIAH) Associate Award No. 7200AA18LA00007. TB DIAH is implemented by the University of North Carolina at Chapel Hill, in partnership with John Snow, Inc. Views expressed are not necessarily those of USAID or the United States government. SR-23-194b KH TB